Australian Government

Job Services Australia

people • skills • jobs

# ជំនួយសម្រាប់អ្នកធ្វើការដែលទើបបាត់បង់ការងារ

លោកអ្នកមានសិទ្ធិទទួលសេវារកការងារធ្វើយ៉ាងឆាប់ហ័ស និងដោយយកចិត្តទុកដាក់ ប្រសិនបើលោកអ្នកបាត់បង់ការងារដោយប្រការណាមួយ ដូចជាការអស់ការងារធ្វើ ការបញ្ឈប់ពីការងារ ការកាត់បន្ថយចំនួនបុគ្គលិក ឬហេតុផលផ្សេងៗទៀតដែលអាចបណ្តាលឱ្យអាជីវកម្មធ្លាក់ចុះ។

លោកអ្នកក៏អាចប្រើប្រាស់សេវាទាំងនេះផងដែរ ប្រសិនបើលោកអ្នកបានទទួលដំណឹងថា លោកអ្នកនឹងត្រូវបាត់បង់ការងារដោយមានការប្រាប់ឲ្យដឹងពីកាលបរិច្ឆេទបញ្ឈប់ការងារ។

គម្រោងផ្តួចផ្តើមជួយរកការងារភ្លាមនៅគ្រាដំបូង ដំណើរការសម្រាប់រយៈពេលពីរឆ្នាំ ហើយជួយអ្នកធ្វើការងារទាំងអស់ ដែលបានបាត់បង់ការងារដោយសារប្រការរៀបរាប់ខាងលើចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១១។ ការផ្តល់ជំនួយរកការងារធ្វើនេះ ចាប់ផ្តើមពីថ្ងៃ ទី១ ខែមេសា ឆ្នាំ២០០៩។

## តើត្រូវចាប់ផ្តើមពីទីណា

### 1. សូមយកលិខិតពីនិយោជករបស់លោកអ្នក លិខិតបញ្ជាក់ពីការផ្តាច់ការងារ (Separation Certificate) ឬឯកសារផ្សេងៗទៀត ដែលជាភស្តុតាងបង្ហាញថា លោកអ្នកបាត់បង់ការងារ ដោយសារតែហេតុផលខាងលើ។ សូមយកសំណុំឯកសារទាំងនេះ ទៅកាន់ Centrelink។

Centrelink នឹងវាយតម្លៃសិទ្ធិរបស់លោកអ្នក សម្រាប់ទទួលសេវាការងារ និងរៀបចំណាត់ពេលវេលាឱ្យលោកអ្នកជួបជាមួយស្ថាប័នផ្តល់សេវាការងារអូស្ត្រាលី (Job Services Australia) ទៅតាមការជ្រើសរើសលោកអ្នក ។

### 2. ជួបជាមួយនឹងស្ថាប័នផ្តល់ Job Services Australia តាមតំបន់របស់លោកអ្នក

ស្ថាប័ន Job Services Australia របស់លោកអ្នក នឹងវាយតម្លៃស្ថានភាពរបស់លោកអ្នកយ៉ាងល្អិតល្អន់ ហើយធ្វើការជាមួយលោកអ្នក ដើម្បីជួយលោកអ្នកឱ្យមានលទ្ធភាពចូលធ្វើការងារវិញឲ្យបានលឿនបំផុតតាមដែលអាចធ្វើបាន។

## ជំនួយដែលលោកអ្នកអាចទទួល

ស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក នឹងធ្វើការជាមួយលោកអ្នកដើម្បីបង្កើតផែនការរកការងារធ្វើ (Employment Pathway Plan) ដែលសមស្របទៅនឹងតម្រូវការផ្ទាល់របស់លោកអ្នកដើម្បីជួយឲ្យលោកអ្នកទទួលបានការងារមួយផ្សេងទៀតឲ្យបានលឿនបំផុតតាមដែលអាចធ្វើបាន។ ផែនការនេះអាចរួមទាំង៖

- ជំនួយក្នុងការរៀបចំប្រវត្តិរូបសង្ខេបរបស់លោកអ្នក និងពាក្យសុំចូលធ្វើការ ជំនាញក្នុងការជួបសម្ភាសន៍ និងបច្ចេកទេសធ្វើបទបង្ហាញ។
- ការណែនាំអំពីការស្វែងរកការងារ ជម្រើសមុខអាជីពផ្សេងៗ និងកម្មវិធីការងារនានា។
- ព័ត៌មានអំពីការប្រកាសរកបុគ្គលិកសម្រាប់ការងារដែលទំនេរ និងការប្រើប្រាស់ឧបករណ៍ស្វែងរកការធ្វើ ដែលផ្តល់ដោយ Centrelink និងស្ថាប័ន Job Services Australia ដោយរួមទាំង JobSearch - **jobseasrch.gov.au** ដែលជាគេហទំព័រស្វែងរកការងារដ៏ធំ និងមានប្រជាប្រិយបំផុតរបស់អូស្ត្រាលី។
- ការបញ្ជូន និងការរកកន្លែងឲ្យរៀនដកពិសោធការងារ។
- ការវាយតម្លៃជំនាញដ៏ទូលំទូលាយ។
- ការអភិវឌ្ឍ និងការបណ្តុះបណ្តាលហ្វឹកហ្វឺនជំនាញដែលពាក់ព័ន្ធនឹងតម្រូវការក្នុងទីផ្សារការងារនៅតាមតំបន់របស់លោកអ្នក និងឱកាសការងារដែលសម្លឹងឃើញជាក់លាក់។
- ការបញ្ជូនលោកអ្នកទៅទទួលការអប់រំ ឬឱកាសបណ្តុះបណ្តាលហ្វឹកហ្វឺន ដោយរួមទាំង កម្មវិធីផ្តល់កន្លែងបង្កើនផលិតភាព (Productivity Places Program) កម្មវិធីបណ្តុះបណ្តាលភាសា អក្ខរកម្ម និងលេខនព្វន្ត (Language, Literacy and Numeracy Program) ឬកម្មវិធីរៀនភាសាអង់គ្លេសសម្រាប់ជនអន្តោប្រវេសន៍ពេញវ័យ (Adult Migrant English Program)។
- ជួយឱ្យទទួលបានអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬចំណេះវិជ្ជាផ្សេងៗទៀត។
- ឱកាសដកពិសោធការងារ។

ស្ថាប័ន Job Services Australia របស់លោកអ្នកនឹងជួបលោកអ្នកជាទៀងទាត់ ដើម្បីពិនិត្យឡើងវិញនូវផែនការរកការងារធ្វើ (Employment Pathway Plan) របស់លោកអ្នក។ ស្ថាប័នទាំងនេះ ក៏នឹងមានលទ្ធភាពទទួលបានមូលនិធិ Employment Pathway ណាមួយដែលគេអាចប្រើប្រាស់សម្រាប់ជាជំនួយដល់ការចំណាយលើការបណ្តុះបណ្តាលហ្វឹកហ្វឺន សម្ភារៈ និងការងារ។

## Productivity Places Program

លោកអ្នកក៏អាចទទួលបានការបណ្តុះបណ្តាលហ្វឹកហ្វឺនកម្រិត Certificate III និងខ្ពស់ជាងនេះផងដែរ សម្រាប់ឧស្សាហកម្ម និងការងារជាច្រើនប្រភេទ ដែលនៅទីនោះ លោកអ្នកអាចមានឱកាសទទួលការងារ។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងស្ថាប័ន Job Services Australia តាមតំបន់របស់លោកអ្នក ឬបើកមើលវិបសាយថ៍ **productivityplaces.deewr.gov.au**។

## Labour Adjustment Packages

កញ្ចប់ទូទាត់សំណងការងារ (Labour Adjustment Packages) គឺមានជូនអ្នកធ្វើការណាដែលត្រូវបានបញ្ឈប់ពីការងារដោយក្រុមហ៊ុនមានសិទ្ធិទទួលជំនួយ មានដូចជាក្រុមហ៊ុនផលិតរថយន្ត ឬឧស្សាហកម្មវាយនភណ្ឌ ផលិតសម្លៀកបំពាក់ និងស្បែកជើង។

តាមរយៈកម្មវិធីទូទាត់សំណងលើផ្នែករចនាសម្ព័ន្ធឧស្សាហកម្មយានយន្ត (Automotive Industry Structural Adjustment Program) និងកម្មវិធីទូទាត់សំណងលើផ្នែករចនាសម្ព័ន្ធឧស្សាហកម្មវាយនភណ្ឌ ផលិតសម្លៀកបំពាក់ និងស្បែកជើង (Textile, Clothing and Footwear Structural Adjustment Program) ស្ថាប័នផ្តល់ Job Services Australia អាចផ្តល់ឲ្យលោកអ្នកនូវជំនួយបន្ថែមតាមតម្រូវការរបស់លោកអ្នក ដើម្បីស្វែងរកការងារផ្សេងទៀត។ ជំនួយបន្ថែមទាំងនេះរួមមាន ប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ ការចំណាយលើការផ្លាស់ប្តូរទីលំនៅ ឬការទទួលជំនាញថ្មី។

2FS09446JSA/khmer

## ជំនួយក្នុងការគ្រប់គ្រងថវិការបស់លោកអ្នក

Centrelink ផ្តល់ការណែនាំដោយឥតគិតថ្លៃ និងដោយមិនលម្អៀង ចំពោះកញ្ចប់ប្រាក់ជំនួយដល់អ្នកបាត់បង់ការងារនិងជំនួយរដ្ឋាភិបាលដល់លោកអ្នក។

សូមកត់ចំណាំថា៖ សិទ្ធិទទួលជំនួយទ្រទ្រង់ប្រាក់ចំណូល គឺអាស្រ័យទៅលើស្ថានភាពផ្ទាល់របស់លោកអ្នក ដោយរួមទាំងប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់លោកអ្នក។ ប្រសិនបើលោកអ្នកមានសិទ្ធិទទួលជំនួយទ្រទ្រង់ប្រាក់ចំណូលនេះ លោកអ្នកអាចនឹងមិនទទួលជំនួយនេះក្នុងមួយរយៈកាល ដោយអាស្រ័យទៅលើប្រាក់កម្រៃនៃការឈប់សម្រាក ឬប្រាក់កម្រៃផ្តល់ជូនលោកអ្នកនៅពេលដែលលោកអ្នកបាត់បង់ការងារ។

សម្រាប់ព័ត៌មានបន្ថែមសូមទូរស័ព្ទទៅ Centrelink **13 24 90** ឬបើកមើលវិបសាយថ៍ **centrelink.gov.au**។

## Special Child Care Benefit

ក្នុងពេលដែលអស់ការងារធ្វើ ប្រសិនបើលោកអ្នកមានការលំបាកក្នុងការចំណាយលើថ្លៃថែទាំកូនឬកុមារ លោកអ្នកអាចមានសិទ្ធិទទួលប្រាក់បំណាច់ពីការថែទាំកុមារជាពិសេស (Special Child Care Benefit)។ ចំពោះព័ត៌មានបន្ថែមសូមទាក់ទងការិយាល័យជំនួយគ្រួសារ (Family Assistance Office) តាមទូរស័ព្ទលេខ **13 61 50**។

## General Employee Entitlements and Redundancy Scheme

ប្រសិនបើលោកអ្នកបាត់បង់ការងារ ដោយសារនិយោជករបស់លោកអ្នកក្ស័យធន ឬជំពាក់បំណុលលើសលប់ ហើយមានថវិកាមិនគ្រប់គ្រាន់សម្រាប់ផ្តល់ជូនលោក នូវប្រាក់បំណាច់ដែលលោកអ្នកត្រូវទទួលបាន លោកអ្នកអាចទទួលជំនួយតាមរយៈ គម្រោងទូទៅសម្រាប់ការបាត់បង់ការងារ និងសិទ្ធិរបស់និយោជិតក្នុងការទទួលប្រាក់បំណាច់ (General Employee Entitlements and Redundancy Scheme [GEERS] )។

ចំពោះព័ត៌មានបន្ថែមសូមទូរស័ព្ទទៅ GEERS តាមរយៈលេខ **1300 135 040** ឬបើកមើលវិបសាយថ៍ **workplace.gov.au/geers**។

## Securing Apprenticeships Program

ប្រសិនបើលោកអ្នកជាអ្នកហាត់រៀនការងារជំនាង ឬអ្នកហ្វឹកហាត់ការងារដទៃទៀត ដែលត្រូវគេបញ្ឈប់ពីការងារនោះ កម្មវិធីធានាសម្រាប់អ្នកហាត់ការងារ (Securing Apprenticeships Program) អាចជួយលោកអ្នកឱ្យហ្វឹកហាត់ការងារបន្តទៀត ដើម្បីឱ្យលោកអ្នកទទួលបានការបណ្តុះបណ្តាលចប់សព្វគ្រប់។

ជំនួយសម្បាទានដល់បៀវត្សរ៍សម្រាប់ Securing Apprenticeships គឺមានសម្រាប់បណ្តានិយោជករួមទាំងក្រុមអង្គការបណ្តុះបណ្តាលហ្វឹកហ្វឺនដែលណែនាំអ្នកហាត់ការងារ ឬអ្នកហ្វឹកហ្វឺនការងារទាំងនោះ។

ចំពោះព័ត៌មានបន្ថែមសូមទូរស័ព្ទមកបណ្តាញបញ្ជូនរបស់ Australian Apprenticeships លេខ **13 38 73** ឬបើកមើលវិបសាយថ៍ **australianapprenticeships.gov.au** ។

## សិទ្ធិទទួលប្រាក់បំណាច់ពីការបាត់បង់ការងារ

ប្រសិនបើលោកអ្នកត្រូវគេបញ្ឈប់ពីការងារ ហើយគិតថាលោកអ្នកមិនបានទទួលប្រាក់បំណាច់ដែលលោកអ្នកត្រូវទទួលទេនោះ លោកអ្នកអាចទាក់ទងទៅ Fair Work Australia។

Fair Work Australia នឹងជួយលោកអ្នកឱ្យទទួលនូវប្រាក់បំណាច់ដែលគេជំពាក់នោះ

លោកអ្នកអាចទូរស័ព្ទទៅបណ្តាញជំនួយរបស់ Fair Work Ausralia តាមរយៈលេខ **1300 724 200** ។

## ភាតព្វកិច្ចរបស់លោកអ្នក

ប្រសិនបើលោកអ្នកទទួល Newstart ប្រាក់ឧបត្ថម្ភសម្រាប់យុវវ័យ (Youth Allowance) ឬប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) ហើយមានការតម្រូវឲ្យលោកអ្នកចូលរួម លោកអ្នកនឹងត្រូវស្វែងរកការងារធ្វើ ហើយចូលរួមក្នុងសកម្មភាពទាំងឡាយណា ដែលអាចជួយឱ្យលោកអ្នកស្វែងរកការធ្វើបាន។

ស្ថាប័ន Job Services Australia របស់លោកអ្នកនឹងពិចារណាអំពីស្ថានភាពផ្ទាល់របស់លោកអ្នក ហើយចរចាអំពីសកម្មភាពសមស្របទាំងពួងដែលគេនឹងដាក់បញ្ចូលទៅក្នុង Employment Pathway Plan របស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពទាំងនោះ លោកអ្នកគួរពិភាក្សាបញ្ហានេះជាមួយស្ថាប័ន Job Services Australia របស់លោកអ្នក។ ប្រសិនបើលោកអ្នកខកខានមិនបានអនុវត្តតាមសកម្មភាពដែលបានព្រមព្រៀងទេ បញ្ហាប៉ះពាល់ដល់ថវិកាគាំទ្រ ចំណូលរបស់លោកអ្នកអាចកើតមានឡើង។

## សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR], (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុត ដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក DEEWR ឬបើកមើលវិបសាយថ៍ **privacy.gov.au** ។

## ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

### ការធានាសេវា

លោកអ្នកនឹងទទួលបានសេវាការងាររៀបចំឡើងសម្រាប់រូបលោកអ្នកផ្ទាល់ដែលផ្តល់ដោយស្ថាប័នផ្តល់ Job Services Australia ។ សេវាទាំងនេះនឹងមានលក្ខណៈបត់បែនទៅតាមស្ថានភាព និងប្រវត្តិការងាររបស់លោកអ្នក។ ដើម្បីមើលពីការធានារបស់សេវាទាំងអស់នេះ សូមចូលទៅវិបសាយថ៍ **deewr.gov.au/jobservicesaustralia** ។

### ក្រមសីលធម៌វិជ្ជាជីវៈ

ស្ថាប័នផ្តល់ Job Services Australia ចុះកិច្ចសន្យាដើម្បីផ្តល់សេវាការងារដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី និងបានយល់ព្រម ហើយប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការផ្តល់សេវាការងារនេះ។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវៈ សូមចូលទៅវិបសាយថ៍ **deewr.gov.au/jobservicesaustralia**។

## សម្រាប់ព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវិបសាយថ៍ deewr.gov.au/jobservicesaustralia**

**សូមទូរស័ព្ទទៅ Centrelink តាមរយៈលេខ 13 28 50 ឬបើកមើលវិបសាយថ៍ centrelink.gov.au**

**សម្រាប់ការណែនាំអំពីការដោះស្រាយភាពអស់ការងារធ្វើ សូមបើកមើល Beyond Blue តាមរយៈវិបសាយថ៍ beyondblue.org.au ។**